**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

លេខៈ ១១០៥ មស.

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅ
# របស់អគ្គាធិការដ្ឋានមុខងារសាធារណៈ

## រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ២០ នស.រកម ០១៩៦-២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**ប្រការ ១.-**

អគ្គាធិការដ្ឋាន ជាសេនាធិការសំខាន់របស់ថ្នាក់ដឹកនាំ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មានមុខងារ និងភារកិច្ច ដូចតទៅ:

- សិក្សាស្រាវជ្រាវរៀបចំផែនការអធិការកិច្ច ប្រចាំឆ្នាំក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ដើម្បីសុំការសម្រេចពីប្រធានស្ថាប័ន។
- ធ្វើអធិការកិច្ចក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត ក្រុង ក្នុងវិស័យមុខងារសាធារណៈ និងរាយការណ៍ជូនរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។
- សហការសិក្សាស្រាវជ្រាវ រាល់ពាក្យបណ្តឹង តវ៉ា បរិហារ របស់មន្ត្រីរាជការស៊ីវិល។
- គ្រប់របាយការណ៍នៃការធ្វើអធិការកិច្ចត្រូវរក្សាការសម្ងាត់ជាដាច់ខាត ប្រធានស្ថាប័នជាអ្នកសម្រេចចំពោះការផ្សព្វផ្សាយនូវរបាយការណ៍អធិការកិច្ចទាំងនោះ។
- ប្រតិបត្តិការភារកិច្ចតាមបញ្ជា របស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**ប្រការ ២.–**

អគ្គាធិការដ្ឋាន មានការិយាល័យអធិការកិច្ចចំណុះចំនួន៣៖

១- ការិយាល័យអធិការកិច្ចរដ្ឋបាល និងសរុប

២- ការិយាល័យអធិការកិច្ចមុខងារសាធារណៈ

៣- ការិយាល័យអធិការកិច្ច គណនេយ្យ និង ហិរញ្ញវត្ថុ

ការិយាល័យនីមួយៗត្រូវបែងចែកមុខការដោយកំណត់ផ្ទៃក្នុង ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

**ប្រការ ៣.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.–**

អគ្គនាយកនៃ អគ្គនាយកដ្ឋានមុខងារសាធារណៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២

**រដ្ឋលេខាធិការ**

**ពេជ្រ ប៊ុនធិន**

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

  " ដើម្បីជូនជ្រាប"
- ដូចប្រការ ៤
- ឯកសារ–កាលប្បវត្តិ